00333414

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28 / MAY / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/21

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / MAY / 2009
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩-ថ្ងៃទី ១៧

រៀបចំដោយ: សែ កុលវុឌ្ឍី និង Natacha-Wexel-Riser

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Matteo CRIPPA,លោក ឌុច ផារី,លោកស្រី សែ កុលវុឌ្ឍី,កញ្ញា Natacha-Wexel-Riser |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក តាន់ សេណារ៉ុង, លោក Alexander Bates<br>លោក ពេជ្រ សម្បត្តិ,លោក ប៉ាក ចន្ទលីណូ,លោក Stuart Ford |
| ជនជាប់ចោទ៖ កាំង ហ្គេកអ៊ាវ ហៅ ឌុច |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

| | |
|---|---|
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ,លោក François Roux, លោកស្រី Heleyn Unac លោក ចាន់ រ៉ាវុធ,កញ្ញា Lucile Nattiez | |
| មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖ លោក គង់ ពិសី, លោក ហុង គីម សួន,យុង ផានិត,កញ្ញា Silke Studzinsky, លោក Alain Werner,កញ្ញា ទី ស្រីនណា, លោកស្រី Elisabeth Rabesandratana, កញ្ញា ម៉ុច សុវណ្ណារី | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ | |
| ផ្នែកផ្សេងៗ៖ លោកស្រី Maryvonne Maniacky,លោក សាន គីរី,លោក សំ មករា, កញ្ញា Julie Massé | |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ ១៦.២៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤៥ | បញ្ចប់ម៉ោង៖ ១១.៣០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៤.៣០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៣៥ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការបន្តតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុនៃការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ | អង្គជំនុំជម្រះ | ៩.១៥ | |
| សេចក្តីសម្រេចលើការជំទាស់ដែលលើកដោយមេធាវីការពារក្តី | អង្គជំនុំជម្រះ | ១៤.៣០ | ១៤.៤៥ |
| ការបន្តតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុនៃការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ | អង្គជំនុំជម្រះ | ១៤.៤៥ | ១៥.៤២ |



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C.

| | | | |
|---|---|---|---|
| សំណើសុំការណែនាំទៅលើវិធាន៨៧.២ និង ៨៧.៣ និងយោបល់ពីភាគីទាំងអស់ | សហព្រះរាជអាជ្ញា | ១៥.៤២ | ១៦.២០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធី៖**

**ការតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១**

- អង្គជំនុំជម្រះបានបន្តតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុនៃការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ ។
- មេធាវីការពារក្តីបានជំទាស់ទៅនឹងការលើកឡើងរបស់អ្នកជំនាញទាក់ទងនឹងឯកសារលេខ D73, D56 ឧបសម្ព័ន្ធ១, E5/2.21, ដែលឯកសារទាំងនេះបានដាក់នៅក្នុងសំណុំរឿងបន្ទាប់ពីរបាយការណ៍របស់អ្នកជំនាញបានបំពេញចប់សព្វគ្រប់។

**សេចក្តីសម្រេចលើការជំទាស់ដែលលើកដោយមេធាវីការពារក្តី**

- អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ទៅលើការជំទាស់ដែលបានលើកដោយមេធាវីការពារក្តី (សូមមើលខាងក្រោម)

**ការតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១**

- អង្គជំនុំជម្រះបានបន្តតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុនៃការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ ។

**សំណើសុំការណែនាំពីអង្គជំនុំជម្រះទៅលើវិធាន ៨៧.២ និង ៨៧.៣**

- សហព្រះរាជអាជ្ញាបានស្នើសុំការណែនាំពីអង្គជំនុំជម្រះទៅលើការអនុវត្តន៍នៃវិធាន៨៧.៣ និងវិធីសាស្ត្រនៃការដាក់ឯកសារដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីចងក្រងជាភស្តុតាង សហព្រះរាជអាជ្ញាបានស្នើថាភាគីទាំងអស់ត្រូវដាក់នូវបញ្ជីឯកសារជាមួយសេចក្តីសង្ខេប

ជាលាយលក្ខណ៍អក្សរនៃរាល់ឯកសារទាំងអស់។ បន្ទាប់មកត្រូវអានសេចក្តីសង្ខេបនោះដោយផ្ទាល់មាត់នៅក្នុងតុលាការ ជាជាងការធ្វើសេចក្តីសង្ខេបនៃឯកសារនីមួយៗ។សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវតែដាក់ចូលក្នុងសំណុំរឿង ដើម្បីឱ្យមានប្រសិទ្ធិភាព។

- មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំក្នុងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរគាំទ្រចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។
- មេធាវីការពារក្តីបានបង្ហាញនៅភាពមិនច្បាស់លាស់ថាតើឯកសារទាំងនេះត្រូវការឬទេ ហើយយោងតាមវិធាន ៨៥ នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីស្នើសុំឱ្យសហព្រះរាជអាជ្ញា ជ្រើសរើសយកតែឯកសារណាដែលមានការពាក់ព័ន្ធ ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីក្នុងវិធាន ៨៧.២</u>**

| លេខយោងរបស់អង្គជំនុំជម្រះ | លេខយោងរបស់សហចៅក្រមស៊ើបអង្កេត | ឈ្មោះ/ពិពណ៌នា | ចំណាត់ថ្នាក់ឯកសារ(សម្ងាត់ដាច់ខាត,សម្ងាត់សាធារណៈ) | ផ្សេងៗ |
|---|---|---|---|---|
| E3/38 | D55 | សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកកម្រងបញ្ជីអ្នកទោសមន្ទីរស២១ | សាធារណៈ | 00172353-00172255 និង00172349-00172352 |
| E3/38-ឧបសម្ព័ន្ធក | D55-ឧបសម្ព័ន្ធក | បញ្ជីអ្នកទោសស២១ ( ១៩៧៥ ដល់ ១៩៧៨ ) | សាធារណៈ | 00171429-00171798 |
| E3/39 | IS 13.42 | កំណត់ហេតុនៃការប្រជុំលេខា- អនុលេខាកងពលនិងវរៈសេនាធំឯករាជ្យ ថ្ងៃទី០១ ខែ មិនា ឆ្នាំ១៩៧៧ | សាធារណៈ | 00183949-00183955 |
| E3/40 | D64-ឧបសម្ព័ន្ធ២៩ | ឧបសម្ព័ន្ធ ២៩ របាយការណ៍ពី ស៊ូ ម៉េត ទៅ កាំង ហ្គេកអ៊ាវ | សាធារណៈ | 00002409-00002409 |
| E3/32 | D2-15 | កំណត់នៃការវិភាគរបស់លោកCraig | សាធារណៈ | 00146872 មាននៅក្នុងប្រអប់ |

| | | | | |
|---|---|---|---|---|
| | | Etcheson អ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញា ជើងទំព័រ ២៨៥ និង ២៨៦ | | E3 រួចហើយ មិនចាំបាច់ជូនដំណឹងទេ |
| E3/41 | D73 | "បញ្ជីរាយនាមបុគ្គលិកនៃមន្ទីរសន្តិសុខមួយចំនួនផ្សេងទៀត ដែលត្រូវចាប់ហើយបញ្ជូនមកស២១" "កំណត់ហេតុសួរចម្លើយឌុច ដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០០៨ | សាធារណៈ | 00209180-00209182 |
| E5/2.21 | គ្មាន | ចម្លើយសារភាពមន្ទីរស២១ របស់ កែវ មាស ហៅ អាចារ្យកង | សាធារណៈ | 00284015-00284019<br>និង 00294500-00294504 |
| E3/42 | D56-ឧបសម្ព័ន្ធ ១ | ឧបសម្ព័ន្ធ១ដែលមានចំណងជើងថា "អំពីឈ្មោះបុគ្គលដែលបានចូលរួម និងពាក់ព័ន្ធនៅក្នុងប្រវត្តិរបស់ ចាប ណម" | សាធារណៈ | 00170595-00170601 |
| E3/27 | IS 9.2 | រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ១៩៧៥ | សាធារណៈ | 00184833-00184839<br>00089841-00089852<br>00012644-00012659<br>មាននៅក្នុងប្រអប់ E3 រួចហើយមិនចាំបាច់ជូនដំណឹងទេ |
| E3/43 | IS 13.3 | ឯកសារនៃសមាជលើកទី១ នៃអង្គនីតិបញ្ញាតិទី១ នៃសភាតំណាងរាស្ត្រកម្ពុជា ថ្ងៃទី១១,១៣ ខែមេសា ឆ្នាំ១៩៧៦ | សាធារណៈ | 00184048-00184078 |
| E3/44 | IS 13.8 | កំណត់ហេតុនៃអង្គប្រជុំការងារមូលដ្ឋាន | សាធារណៈ | 00182628-00182634 |

| | | ថ្ងៃទី០៨ ខែមិនា ឆ្នាំ ១៩៧៦ | | |
|---|---|---|---|---|

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

I.សេចក្តីសម្រេចលើការជំទាស់ដែលលើកដោយមេធាវីការពារក្តី

1. អង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ចទៅនឹងសេចក្តីណែនាំ ឬការចង្អុលបង្ហាញដែលបានប្រគល់ទៅឲ្យភាគីចំពោះវិសាលភាពនៃការផ្តល់សក្ខីកម្មឬរបាយការណ៍របស់អ្នកជំនាញនោះទេ ។

   ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូង និងភាគីមានសិទ្ធិក្នុងការសួរសំណួរដល់អ្នកជំនាញក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណួរទាំងនោះមានភាពពាក់ព័ន្ធ ។ នៅពេលឆ្លើយទៅនឹងសំណួរទាំងនោះអ្នកជំនាញមិនត្រូវបានចងភ្ជាប់ទៅនឹងរបាយការណ៍ ឬសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលបានដាក់ពីមុននោះទេ ។ អ្នកជំនាញមិនមាននូវកាតព្វកិច្ចក្នុងការដាក់នូវរបាយការណ៍ជាលាយលក្ខណ៍អក្សរបន្ថែមនោះទេ ។

2. ជាទូទៅដើម្បីដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ រាល់ឯកសារទាំងអស់ត្រូវតែមានជាបីភាសារបស់តុលាការ ប៉ុន្តែអង្គជំនុំជម្រះនឹងទទួលយកនូវការយោងទៅលើឯកសារទាំងឡាយណាដែលមានជាភាសាខ្មែរ និងភាសាផ្លូវការមួយទៀតរបស់តុលាការ ។

   ដោយហេតុថា៖

   ក) អ្នកនិយាយភាសាខ្មែរមាននៅក្នុងគ្រប់ភាគីទាំងអស់ និងនៅក្នុងអង្គជំនុំជម្រះសាលាដំបូងផងដែរ ។

   ខ) ធនធាននៃការបកប្រែនៅមានកម្រិត ហើយមានឯកសារជាច្រើនក្នុងសំណុំរឿងដែលត្រូវបកប្រែ ។

   គ) យោងតាមវិធាន២១ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចក្នុងការរៀបចំដំណើរការសវនាការប្រកបដោយភាពយុត្តិធម៌

និងបញ្ចប់ក្នុងរយៈពេលមួយដែលសមស្រប ។

មានករណីលើកលែងចំពោះវិធាននេះ ដែលករណីមួយនៃការលើកលែងនេះ គឺក្នុងករណីដែលឯកសារត្រូវលើកឡើង ហើយមិនបានជូនដំណឹងជាមុននោះ ភាគីអាចជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារនោះ ឬអាចស្នើសុំពន្យារ សុំពេលវេលាបន្ថែមដើម្បីធ្វើការពិនិត្យពិចារណាលើឯកសារនោះបាន ។

3. រាល់ការបកប្រែទាំងអស់នឹងត្រូវបានទទួលយកដោយតុលាការ លើកលែងតែមានការជំទាស់ទាក់ទងនឹងភាពត្រឹមត្រូវ និងភាពស៊ីសង្វាក់គ្នារវាងឯកសារទាំងនោះ ។ ការលើកឡើងនូវការជំទាស់នោះត្រូវមានមូលហេតុច្បាស់លាស់ ។

តុលាការសូមរំឭកដល់ភាគីថា ឯកសារដោយរួមបញ្ចូលទាំងឯកសារ ដែលលើកឡើងដោយអ្នកជំនាញត្រូវតែបានអានឬសង្ខេប ដើម្បីយកមកពិចារណានៅចំពោះមុខអង្គជំនុំជម្រះ ។

<u>សេចក្តីសម្រេច</u>៖

ការជំទាស់ដែលបានលើកឡើងដោយមេធាវីការពារជនជាប់ចោទ ទាក់ទងនឹងវិសាលភាពនៃការធ្វើសក្ខីកម្មរបស់អ្នកជំនាញ Craig Etcheson ដែលថាគាត់គួរតែដាក់នូវរបាយការណ៍បន្ថែម ហើយដែលថាការបកប្រែមិនបានធ្វើឡើង ដោយអង្គភាពបកប្រែរបស់អង្គជំនុំជម្រះ ក្នុងតុលាការកម្ពុជានោះត្រូវបដិសេធចោល ។

ឯកសារ D56 ដែលគេស្គាល់ថាជាចម្លើយសារភាពរបស់ ចាប ណម មិនមានការបកប្រែជាភាសាបារាំង ហើយការលើកឡើងនៅឯកសារនោះ ធ្វើឡើងដោយមិនបានដឹងជាមុន ។ មេធាវីការពារជនជាប់ចោទ អាចជ្រើសរើសក្នុងការស្នើសុំពេលវេលាបន្ថែមដើម្បីពិនិត្យលើកឯកសារនោះ ឬអាចស្នើសុំបដិសេធមិនឱ្យទទួលយកនូវឯកសារនោះក្នុងដំណាក់កាលនេះបាន ។

អង្គជំនុំជម្រះសាលាដំបូងនឹងស្នើសុំដល់មេធាវីការពារជនជាប់ចោទ ឱ្យធ្វើការចង្អុលបង្ហាញដោយផ្អែកតាមសេចក្តីសម្រេចនេះថា តើក្រុមរបស់ខ្លួនរក្សានៅជំហរក្នុងការ

បដិសេធទៅនឹងឯកសារយោងលេខ D2-15 ឧបសម្ព័ន្ធ "គ" នៃសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ៣៩ និង ៣០ នឹងដោយធ្វើការបញ្ជាក់លើឯកសារយោងទាំងនេះ និងប្រសិនបើក្រុមរបស់ខ្លួនរក្សានូវជំហរក្នុងការបដិសេធលើឯកសារទាំងនេះ សូមបញ្ជាក់នូវមូលហេតុនៃការជំទាស់នេះឲ្យបានច្បាស់លាស់ត្រឹមម៉ោង ៩ព្រឹកថ្ងៃស្អែក ។

II-អង្គជំនុំជម្រះបានសម្រេចថាឯកសារលេខ D2-15 ឧបសម្ព័ន្ធ គ លេខ ៣៩ មិនត្រូវយោងនោះទេ រហូតដល់មានការបញ្ជាក់ត្រូវបានធ្វើដោយសហព្រះរាជអាជ្ញា។

III-ដីកាបង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៩ ។

| <u>ដីកាសម្រាប់ការលើកវារកាលសវនាការ</u> |
|---|
| ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃពុធ ទី២០ ខែឧសភា ឆ្នាំ ២០០៩ វេលាម៉ោង ១០.៣០ព្រឹក ។ |

ភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុណវឌ្ឍី Natacha-Wexel-Riser